0097

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
៣៣៣*៣៣

**សាលាដំបូង**
**ខេត្តឧត្តរមានជ័យ**
រណ៉ុំរឿងរដ្ឋប្បវេណីលេខ ០៨៧
:ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩
ាលក្រមលេខ ០៩ "គ"
:ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៩

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តឧត្តរមានជ័យ

បង្កើតឡើងតាមច្បាប់ស្តីពីអង្គការតុលាការ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខនស/រកម/០៧១៤/ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤។

បានបើកនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៩ វេលាម៉ោង ០៨ និង ៣០នាទី ព្រឹក ដោយមានសមាសភាពដូចតទៅ៖

**ចៅក្រមជំនុំជម្រះ**

លោក **ទ្រី សុភ័គ** អនុប្រធានសាលាដំបូងខេត្តឧត្តរមានជ័យ

**ក្រឡាបញ្ជីសវនាការ**

លោក **គីម លាភហេង** ក្រឡាបញ្ជីសាលាដំបូងខេត្តឧត្តរមានជ័យ

រវាងដើមចោទ **ធនាគា** ដ អាសយដ្ឋានអគារលេខ៖ រាជធានីភ្នំពេញ ដោយមានលោក តជ និងលោក **គា សក្កា** ជាមេធាវីតំណាងដោយអាណត្តិ ។

និងសហចុងចម្លើយឈ្មោះ ច១ ភេទប្រុស អាយុ៣៥ឆ្នាំ និងប្រពន្ធឈ្មោះ ច២ អាយុ៣១ឆ្នាំ សញ្ជាតិខ្មែរ មានលំនៅដ្ឋាននៅភូមិ ខេត្តឧត្តរមានជ័យ ។

## <u>អង្គហេតុនិងចំណុចវិវាទ</u>

### ១.ខ្លឹមសារនៃសាលក្រមដែលទាមទារដោយដើមចោទ៖

១.បង្គាប់ឲ្យសហចុងចម្លើយឈ្មោះ ច១ និងប្រពន្ធឈ្មោះ ច២ រួមគ្នាសងប្រាក់ចំនួន ២៩.០០០ USD (ម្ភៃប្រាំបួនពាន់ដុល្លាអាមេរិកគត់ ) ។

២.បង្គាប់ឲ្យសហចុងចម្លើយសងការប្រាក់គិតចាប់ពីថ្ងៃទី២៦ ខែសីហា ឆ្នាំ ២០១៨ រហូតដល់ថ្ងៃទូទាត់ចប់សព្វគ្រប់ក្នុងអត្រាការប្រាក់១៣,២%(ដប់បីក្បៀសពីរភាគរយ) ក្នុងមួយឆ្នាំ លើប្រាក់ដើមចំនួន ២៩.០០០ USD (ម្ភៃប្រាំបួនពាន់ដុល្លាអាមេរិកគត់ ) តាមកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៨ ។

៣.បង្គាប់ឲ្យសហចុងចម្លើយសងការប្រាក់ពិន័យគិតចាប់ពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៨ រហូតដល់ថ្ងៃទូទាត់ចប់សព្វគ្រប់ក្នុងអត្រាស្មើនឹង ២ដង នៃការប្រាក់ដូចដែលមានចែងក្នុងកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៨ ។

៤.ថ្លៃសេវាកម្មច្បាប់ ការខាតបង់ពេលវេលា និងសំណងជម្ងឺចិត្ត ៥.០០០ USD(ប្រាំពាន់ដុល្លាអាមេរិកគត់) ។

កំណត់សំគាល់៖ សាលក្រមនេះជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ

៥.ប្រាក់ប្រដាប់ក្ដី និងការចំណាយលើនីតិវិធីតុលាការជាបន្ទុករបស់សហចុងចម្លើយ ។

៦.ស្នើសុំអនុវត្តសាលក្រមជាបណ្ដោះអាសន្នត្រង់ចំណុច (១,២ និង ៣)

**២.អង្គហេតុសង្ខេប៖**

តាមពាក្យបណ្ដឹងចុះថ្ងៃទី២៥ ខែមិនា ឆ្នាំ២០១៩ របស់**ធនាគា** ដ

ដែលដើមចោទបានបញ្ជាក់ថា:កាលពីថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៨ សហចុងចម្លើយ ឈ្មោះ ចា១ និងឈ្មោះ ចា២ បានចុះកិច្ចសន្យាខ្ចីប្រាក់ពីធនាគារ ដ ចំនួន ៣០. ០០០ USD (សាមសិបពាន់ដុល្លាអាមេរិកគត់)តាមអត្រាការប្រាក់១៣,២%ក្នុងមួយឆ្នាំដែលមានរយៈពេលខ្ចី ៦០ ខែដោយធ្វើការបង់រំលស់ប្រាក់ដើមនិងការប្រាក់ជារៀងរាល់ខែគិតចាប់ពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨ រហូត ដល់ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៣ ហើយរបៀបនៃការសងប្រាក់ត្រូវអនុវត្តតាមតារាងកាលវិភាគសងប្រាក់របស់ធនាគារ ដោយសងត្រូវកាត់យកដោយស្វ័យប្រវត្តិពីគណនីរបស់សហចុងចម្លើយដូចដែលមានចែងក្នុងប្រការ ១.២ នៃកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៨ ។ ក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួនសហចុងចម្លើយមិនបានគោរពតាមកិច្ចសន្យានៃការបង់ប្រាក់តាមកិច្ចសន្យាឡើយ ដោយខកខានបង់ការប្រាក់និង ប្រាក់ដើមមកធនាគារអស់ជាច្រើនខែមកហើយដោយសហចុងចម្លើយមិនព្រមចូលខ្លួនមកដោះស្រាយឡើយ។

**៣.ចំណុចវិវាទ៖**

សហចុងចម្លើយពុំបានចូលខ្លួនមកឆ្លើយដោះសារក្នុងអង្គហេតុនេះឡើយ ។

**<u>សំអាងហេតុ</u>**

តាមលទ្ធផលនៃការសាកសួរ និងពិនិត្យភស្តុតាង ក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់៖

-លោក **គា សក្កា** ជាមេធាវីតំណាងដោយអាណត្តិ បានបញ្ជាក់ថា៖ កាលពីថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៨ សហចុងចម្លើយឈ្មោះ ចា១ និងឈ្មោះ ចា២ បានចុះកិច្ចសន្យាខ្ចីប្រាក់ពីធនាគារ ដ ចំនួន៣០.០០០USD (សាមសិបពាន់ដុល្លាអាមេរិកគត់)តាមអត្រាការប្រាក់១៣,២% ក្នុងមួយឆ្នាំ ដែលមានរយៈពេលខ្ចី ៦០ ខែដោយធ្វើការបង់រំលស់ប្រាក់ដើមនិងការប្រាក់ជារៀងរាល់ខែគិតចាប់ពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨ រហូត ដល់ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៣ ហើយរបៀបនៃការសងប្រាក់ត្រូវអនុវត្តតាមតារាងកាលវិភាគសងប្រាក់របស់ធនាគារ ដោយសងត្រូវកាត់យកដោយស្វ័យប្រវត្តិពីគណនីរបស់សហចុងចម្លើយ ដូចដែលមានចែងក្នុង ប្រការ ១.២ នៃកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៨ ។ ក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួនសហចុងចម្លើយ មិនបានគោរពតាមកិច្ចសន្យានៃការបង់ប្រាក់តាមកិច្ចសន្យាឡើយដោយខកខានបង់ការប្រាក់និង ប្រាក់ដើម មកធនាគារអស់ជាច្រើនខែមកហើយដោយ សហចុងចម្លើយមិនព្រមចូលខ្លួនមកដោះស្រាយឡើយ។ ហេតុដូច្នេះហើយដើមចោទស្នើសុំទាមទារដូចខាងក្រោម៖

១.បង្គាប់ឲ្យសហចុងចម្លើយឈ្មោះ ចា១ និងឈ្មោះ ចា២ រួមគ្នាសងប្រាក់ចំនួន ២៩.០០០ USD (ម្ភៃប្រាំបួនពាន់ដុល្លាអាមេរិកគត់ ) ។

២.បង្គាប់ឲ្យសហចុងចម្លើយសងការប្រាក់គិតចាប់ពីថ្ងៃទី២៦ ខែសីហា ឆ្នាំ ២០១៨ រហូតដល់ថ្ងៃទូទាត់ចប់សព្វគ្រប់ក្នុងអត្រាការប្រាក់១៣,២%(ដប់បីក្បៀសពីរភាគរយ) ក្នុងមួយឆ្នាំ លើប្រាក់ដើមចំនួន ២៩.០០០ USD (ម្ភៃប្រាំបួនពាន់ដុល្លាអាមេរិកគត់ ) តាមកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៨ ។

កំណត់សំគាល់៖ សាលក្រមនេះជារឿងក្ដីជាក់ស្ដែង ហើយមិនមែនជាសាលក្រមគំរូទេ

៣.បង្គាប់ឲ្យសហចុងចម្លើយសងការប្រាក់ពិន័យគិតចាប់ពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៨ រហូតដល់ថ្ងៃទូទាត់ចប់សព្វគ្រប់ក្នុងអត្រាស្មើនឹង ២ដង នៃការប្រាក់ដូចដែលមានចែងក្នុងកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៨ ។

៤.ថ្លៃសេវាកម្មច្បាប់ ការខាតបង់ពេលវេលា និងសំណងជម្ងឺចិត្ត ៥.០០០ USD(ប្រាំពាន់ដុល្លាអាមេរិកគត់) ។

៥.ប្រាក់ប្រដាប់ក្ដី និងការចំណាយលើនីតិវិធីតុលាការជាបន្ទុករបស់សហចុងចម្លើយ ។

៦.ស្នើសុំអនុវត្តសាលក្រមជាបណ្ដោះអាសន្នត្រង់ចំណុច (១,២ និង ៣)

+ដើមចោទនៅតែរក្សាការទាមទារដូចមាននៅក្នុងពាក្យបណ្ដឹងចុះថ្ងៃទី២៥ ខែមិនា ឆ្នាំ២០១៩ ដដែលដោយពុំមានអ្វីបន្ថែមទៀតនោះទេ ។ ខ្លួនសូមដាក់ជូនតុលាការនូវវត្ថុតាងជាឯកសារដូចខាងក្រោម៖

-តារាងសង្ខេបបំណុលចុងក្រោយ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៩ ។

-តារាងបង់រំលស់ការប្រាក់ និងប្រាក់ដើម ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៩ ។

-កិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៨ ។

-កិច្ចសន្យាដាក់បញ្ចាំ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៨ ។

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់លោក ច១ និងឈ្មោះ ច២ ។

-តាមការពិនិត្យកិច្ចសន្យាដែលដើមចោទបានដាក់ជូនតុលាការ ឃើញថាសហចុងចម្លើយពិតជាបានខ្ចីចងការប្រាក់ពីដើមចោទពិតប្រាកដមែន ។

-បណ្ដឹងទាមទារប្រាក់របស់ដើមចោទដែលមានប្រាក់ដើមចំនួន២៩.០០០ USD(ម្ភៃប្រាំបួនពាន់ដុល្លារ**អាមេរិកគត់**) ,បង្គាប់ឲ្យសហចុងចម្លើយសងការប្រាក់គិតចាប់ពីថ្ងៃទី២៦ ខែសីហា ឆ្នាំ ២០១៨ រហូតដល់ថ្ងៃទូទាត់ចប់សព្វគ្រប់ក្នុងអត្រាការប្រាក់ ១៣,២% (ដប់បីក្បៀសពីរភាគរយ) ក្នុងមួយឆ្នាំ លើប្រាក់ដើមចំនួន ២៩.០០០ USD (ម្ភៃប្រាំបួនពាន់ដុល្លាអាមេរិកគត់ ) តាមកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៨, បង្គាប់ឲ្យសហចុងចម្លើយសងការប្រាក់ពិន័យគិតចាប់ពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៨ រហូតដល់ថ្ងៃទូទាត់ចប់សព្វគ្រប់ក្នុងអត្រាស្មើនឹង ២ដង នៃការប្រាក់ដូចដែលមានចែងក្នុងកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៨ និង ថ្លៃសេវាកម្មច្បាប់ ការខាតបង់ពេលវេលា និងសំណងជម្ងឺចិត្ត ៥.០០០ USD(ប្រាំពាន់ដុល្លាអាមេរិកគត់) មានលក្ខណៈសមស្របតាមច្បាប់ ព្រោះថាតាមការពិនិត្យតារាងស្ដីពីស្ថានភាពបំណុលយឺតយ៉ាវដែលដើមចោទដាក់មកតុលាការនោះឃើញថាសហចុងចម្លើយ ពិតជាពុំបានបង់ការប្រាក់តាមការកំណត់ពិតប្រាកដមែន ហេតុនេះតុលាការគប្បីទទួលស្គាល់ការទាមទារនេះ ។

-បណ្ដឹងសុំអនុវត្តសាលក្រម ជាបណ្ដោះអាសន្នរបស់អ្នកតំណាងដោយអាណត្តិ ឲ្យដើមចោទមានលក្ខណៈសមស្របតាមច្បាប់ តុលាការគប្បីលើកយកមកពិចារណា ដោយយោងតាមមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

-ប្រាក់ប្រដាប់ក្ដីយោងតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី គប្បីជាបន្ទុករបស់សហចុងចម្លើយ។

-តាមចំណាររបស់មន្ត្រីទទួលបន្ទុកអនុវត្តដីកាបញ្ជូនរបស់សាលាដំបូងខេត្តឧត្តរមានជ័យ បានយកដីកាកោះរបស់ឈ្មោះ ច១ និងប្រពន្ធឈ្មោះ ច២ ទៅប្រគល់ឲ្យឈ្មោះនេះដល់លំនៅដ្ឋានរួចហើយ

កំណត់សំគាល់៖ សាលក្រមនេះជារឿងក្ដីជាក់ស្ដែង ហើយមិនមែនជាសាលក្រមគំរូទេ

តែត្រូវបានអ្នករស់នៅទីតាំងនោះបញ្ជាក់ថាមិននៅភូមិឃុំនេះទេ ហើយតុលាការធ្វើការចុះផ្សាយជាសាធារណៈរួចហើយដែរ តែសាមីខ្លួននៅតែមិនព្រមចូលខ្លួនមកតុលាការតាមការកំណត់ដោយគ្មានមូលហេតុ ។ យោងតាមមាត្រា២០១ នៃក្រមនីតិវិធីរដ្ឋប្បវេណី តុលាការអាចធ្វើការជំនុំជម្រះបានដោយកំបាំងមុខសហចុងចម្លើយ និងចាត់ទុកថាសហចុងចម្លើយបានសារភាពទៅនឹងអង្គហេតុដែលលើកឡើងដោយដើមចោទ ។

## សេចក្តីសម្រេចចុងក្រោយ៖

**១**.ឲ្យលោក ច១ ភេទប្រុស អាយុ៣៥ឆ្នាំ និងប្រពន្ធឈ្មោះ ច២ ភេទស្រី អាយុ៣១ឆ្នាំ ជាសហចុងចម្លើយសងបំណុល ដូចខាងក្រោមទៅឲ្យធនាគា ដ តំណាងដោយលោក តដ ជាដើមចោទ៖

១.១.បង្គាប់ឲ្យសហចុងចម្លើយឈ្មោះ ច១ និងឈ្មោះ ច២ រួមគ្នាសងប្រាក់ចំនួន ២៩.០០០ USD (ម្ភៃប្រាំបួនពាន់ដុល្លាអាមេរិកគត់ ) ។

១.២.បង្គាប់ឲ្យសហចុងចម្លើយសងការប្រាក់គិតចាប់ពីថ្ងៃទី២៦ ខែសីហា ឆ្នាំ ២០១៨ រហូតដល់ថ្ងៃទូទាត់ចប់សព្វគ្រប់ក្នុងអត្រាការប្រាក់១៣,២%(ដប់បីក្បៀសពីរភាគរយ) ក្នុងមួយឆ្នាំ លើប្រាក់ដើមចំនួន ២៩.០០០ USD (ម្ភៃប្រាំបួនពាន់ដុល្លាអាមេរិកគត់ ) តាមកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៨ ។

១.៣.បង្គាប់ឲ្យសហចុងចម្លើយសងការប្រាក់ពិន័យគិតចាប់ពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៨ រហូតដល់ថ្ងៃទូទាត់ចប់សព្វគ្រប់ក្នុងអត្រាស្មើនឹង ២ដង នៃការប្រាក់ដូចដែលមានចែងក្នុងកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៨ ។

១.៤.ថ្លៃសេវាកម្មច្បាប់ការខាតបង់ពេលវេលា និងសំណងជម្ងឺចិត្តចំនួន៣.០០០.០០០(បីលាន)រៀល ។

**២**.ចំណុចទី ១.១,១.២ និង ១.៣ នៃសេចក្តីសម្រេចក្នុងសាលក្រមនេះ មានអានុភាពអនុវត្តជាបណ្តោះអាសន្ន។

**៣**.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ។

សាលក្រមនេះបានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៩ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៩ ចំពោះមុខដើមចោទ និងកំបាំងមុខសហចុងចម្លើយឈ្មោះ ច១ និងប្រពន្ធឈ្មោះ ច២ ទុកសិទ្ធឲ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ចៅក្រមជំនុំជម្រះ**

**ហត្ថលេខា និងត្រា ទ្រី សុភ័គ**

................................................................................

**បានឃើញ**

**អនុប្រធានសាលាដំបូង**

ទ្រី សុភ័គ

" បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃអង្គារ ១៥កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

ឧត្តរមានជ័យ,ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៩

**ក្រឡាបញ្ជី**

គីម_លាភហេង